ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ១៩១១៦ អពដ

L202506190014TD3518

ថ្ងៃសុក្រ ១០រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៥

# សេចក្តីណែនាំ
# ស្តីពី
# កាតព្វកិច្ចសារពើពន្ធ
# ចំពោះសមាជិកក្រុមប្រឹក្សាភិបាលឬនាយកក្រុមហ៊ុន

អនុលោមតាមមាត្រា៤២ នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ និងប្រការ៤ នៃប្រកាសលេខ ៥៧៥ សហវ.ប្រក.អពដ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីពន្ធលើប្រាក់បៀវត្ស សកម្មភាពបម្រើការងារមានលក្ខណៈសម្គាល់តាមស្ថានភាពដែលនិយោជិតបំពេញសកម្មភាពបម្រើការងាររបស់ខ្លួននៅក្រោមឱវាទរបស់និយោជក។ រូបវន្តបុគ្គលណាម្នាក់ត្រូវបានចាត់ទុកថាជានិយោជិត ហើយត្រូវជាប់ពន្ធលើប្រាក់បៀវត្ស បើសិនរូបវន្តបុគ្គលនោះមានស្ថានភាពបម្រើការងារស្របតាមលក្ខខណ្ឌចំនួនពីរ ក្នុងចំណោមលក្ខខណ្ឌទាំងឡាយដូចខាងក្រោម៖

- គ្មានហានិភ័យនៃការមិនបានទទួលប្រាក់ទូទាត់ចំពោះសកម្មភាពបម្រើការងាររបស់ខ្លួនឡើយ កាលបើរូបវន្តបុគ្គលនោះបានមកធ្វើការតាមទីកន្លែងដែលបានកំណត់ ហើយបានបំពេញការងារដូចមានចែងក្នុងកិច្ចព្រមព្រៀងបម្រើការងារជាទូទៅមួយ ទោះធ្វើដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរក្តី
- រូបវន្តបុគ្គលមិនអាចកំណត់ពេលវេលា និងទីកន្លែងសម្រាប់បំពេញសកម្មភាពបម្រើការងារដោយខ្លួនឯងទេ
- រូបវន្តបុគ្គលពុំចាំបាច់ចំណាយដើមទុន ដើម្បីទិញឧបករណ៍ដែលត្រូវប្រើប្រាស់សម្រាប់បំពេញសកម្មភាពបម្រើការងារ
- រូបវន្តបុគ្គលមិនបំពេញសកម្មភាពបម្រើការងារឱ្យបុគ្គលច្រើននាក់ទេក្នុងពេលតែមួយ។

អនុលោមតាមប្រការ៧ នៃប្រកាសលេខ ៥៧៥ សហវ.ប្រក.អពដ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីពន្ធលើប្រាក់បៀវត្ស ប្រាក់បៀវត្សជាប់ពន្ធគឺជាប្រាក់ចំណូលបៀវត្សទាំងអស់ដែលបានទទួលពីសកម្មភាពបម្រើការងារនានា វៀរលែងតែអត្ថប្រយោជន៍បន្ថែម។ ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ ត្រូវបានកំណត់ដូចខាងក្រោម៖

- ចំពោះនិយោជិតនិវាសនជនរួមមាន ប្រាក់បៀវត្សប្រភពកម្ពុជា ប្រាក់បៀវត្សប្រភពបរទេស រួមទាំងប្រាក់បុរេប្រទាន ប្រាក់ឱ្យខ្ចីឬប្រាក់រំដោះ ដែលនិយោជកបានបើកឱ្យនិយោជិត
- ចំពោះនិយោជិតអនិវាសនជន ប្រាក់បៀវត្សជាប់ពន្ធរួមមាន ប្រាក់បៀវត្សប្រភពកម្ពុជា។

ប្រាក់បៀវត្សប្រចាំខែរបស់និយោជិតនិវាសនជនឬអនិវាសនជន ត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ទោះបីជាប្រាក់បៀវត្សនោះបើកនៅទីណាក៏ដោយ។

ក្នុងន័យនេះ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីការអនុវត្តកាតព្វកិច្ចសារពើពន្ធ ដូចខាងក្រោម៖


អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

**១- កាតព្វកិច្ចពន្ធលើប្រាក់បៀវត្សចំពោះសមាជិកក្រុមប្រឹក្សាភិបាលឬនាយកក្រុមហ៊ុន ដែលស្ថិតក្នុងលក្ខខណ្ឌជានិយោជិត**

សមាជិកក្រុមប្រឹក្សាភិបាលឬនាយកក្រុមហ៊ុន ដែលបានបម្រើការងារនៅក្នុងក្រុមហ៊ុននៅប្រទេសកម្ពុជា រួមទាំងបុគ្គលដែលត្រូវបានចាត់តាំងការងារបណ្ដោះអាសន្នក្នុងរយៈពេលណាមួយ (Secondment) ពីក្រុមហ៊ុនមេ ឬការិយាល័យកណ្ដាលនៅក្រៅប្រទេស ឱ្យបំពេញការងារជាសមាជិកក្រុមប្រឹក្សាភិបាលឬនាយកក្រុមហ៊ុននៅក្នុងប្រទេសកម្ពុជា បើទោះបីជាមានឬគ្មានបណ្ណការងារក៏ដោយ ហើយទទួលបានប្រាក់បៀវត្សពីការបំពេញការងារនោះ ត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ទោះបីជាប្រាក់បៀវត្សនោះបើកនៅទីណាក៏ដោយ។

**ឧទាហរណ៍ទី១៖**

លោក **ក** ជានិវាសនជនដែលបម្រើការងារនៅសាខាក្រុមហ៊ុន **ខ** ដែលធ្វើអាជីវកម្មនៅប្រទេសកម្ពុជា ក្រោមការចាត់តាំងការងារបណ្ដោះអាសន្នសម្រាប់រយៈពេល ២ឆ្នាំ ពីក្រុមហ៊ុនមេនៅប្រទេសជប៉ុន ឱ្យកាន់មុខតំណែងជានាយកប្រតិបត្តិនៃសាខាក្រុមហ៊ុន **ខ**។ លោក **ក** ទទួលបានប្រាក់បៀវត្សចំនួន ២០ ០០០ ០០០ រៀល ដោយប្រាក់បៀវត្សចំនួន ៤ ០០០ ០០០ រៀល បើកនៅប្រទេសកម្ពុជា និង ប្រាក់បៀវត្សចំនួន ១៦ ០០០ ០០០ រៀល បើកដោយក្រុមហ៊ុនមេនៅប្រទេសជប៉ុន។

ករណីនេះ មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សរបស់លោក **ក** នៅសាខាក្រុមហ៊ុន **ខ** នៅប្រទេសកម្ពុជា ស្មើនឹង ២០ ០០០ ០០០ រៀល។

**២- កាតព្វកិច្ចពន្ធកាត់ទុកចំពោះសមាជិកក្រុមប្រឹក្សាភិបាលឬនាយកក្រុមហ៊ុន ដែលមិនស្ថិតក្នុងលក្ខខណ្ឌជានិយោជិត**

ក្នុងករណីសមាជិកក្រុមប្រឹក្សាភិបាលឬនាយកក្រុមហ៊ុន ដែលមិនស្ថិតក្នុងលក្ខខណ្ឌនៃស្ថានភាពបម្រើការងារដូចបានបញ្ជាក់ជូនខាងលើ ហើយបុគ្គលនោះបំពេញសេវានានាក្នុងនាមបុគ្គលអនិវាសនជនបើទោះបីជាមានឬគ្មានបណ្ណការងារក៏ដោយ ឬបុគ្គលនិវាសនជនឬបុគ្គលអនិវាសនជនដែលបំពេញការងារដោយឯករាជ្យ ឱ្យក្រុមហ៊ុននៅប្រទេសកម្ពុជា ត្រូវជាប់ពន្ធកាត់ទុកលើសេវា ដូចមានចែងក្នុងមាត្រា២៥ និងមាត្រា២៦ នៃច្បាប់ស្ដីពីសារពើពន្ធ។

**ឧទាហរណ៍ទី២៖**

លោក **គ** ជាអនិវាសនជន ជាបុគ្គលិករបស់ក្រុមហ៊ុនមេនៅប្រទេសជប៉ុន និងត្រូវបានចាត់តាំងឱ្យធ្វើជាសមាជិកក្រុមប្រឹក្សាភិបាលនិងអ្នកប្រឹក្សាយោបល់នៅក្រុមហ៊ុន **ឃ** ជាក្រុមហ៊ុនបុត្រសម្ព័ន្ធនៅប្រទេសកម្ពុជា។ ក្រុមហ៊ុនមេនៅប្រទេសជប៉ុនបានគិតកម្រៃសេវាពីក្រុមហ៊ុន **ឃ** ចំនួន ៤ ០០០ ០០០ រៀល ជាប្រចាំខែ ចំពោះការចាត់តាំងលោក **គ** មកចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងអ្នកប្រឹក្សាយោបល់។

ករណីនេះ ការទូទាត់កម្រៃសេវានេះ មិនត្រូវចាត់ទុកជាប្រាក់បៀវត្សរបស់លោក **គ** និងមិនជាប់ពន្ធលើប្រាក់បៀវត្សទេ ប៉ុន្តែត្រូវជាប់ពន្ធកាត់ទុកតាមអត្រា ១៤% និងត្រូវអនុវត្តតាមវិធាននិងនីតិវិធីសម្រាប់បែងចែកចំណូលនិងចំណាយក្នុងចំណោមបុគ្គលទាក់ទិន។

**ឧទាហរណ៍ទី៣៖**

លោក **ង** ជាអនិវាសនជន ជាបុគ្គលិករបស់ក្រុមហ៊ុនមេនៅប្រទេសជប៉ុន និងត្រូវបានចាត់តាំងឱ្យធ្វើជាសមាជិកក្រុមប្រឹក្សាភិបាលនិងអ្នកប្រឹក្សាយោបល់នៅក្រុមហ៊ុន **ឃ** ជាក្រុមហ៊ុនបុត្រសម្ព័ន្ធនៅប្រទេស

L202506190014TD3518

កម្ពុជា។ ក្រុមហ៊ុនមេនៅប្រទេសជប៉ុន មិនគិតកម្រៃសេវាពីក្រុមហ៊ុន **ឃ** ទេ ចំពោះការចាត់តាំងលោក **ង** មកចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងអ្នកប្រឹក្សាយោបល់។

ករណីនេះ ក្រុមហ៊ុន **ឃ** ត្រូវអនុវត្តតាមវិធាននិងនីតិវិធីសម្រាប់បែងចែកចំណូលនិងចំណាយក្នុងចំណោមបុគ្គលទាក់ទិន ចំពោះសេវាដែលបានបំពេញដោយលោក **ង** ដែលជាអនិវាសនជនជាបុគ្គលិករបស់ក្រុមហ៊ុនមេ និងអនុវត្តអត្រាពន្ធកាត់ទុក ១៤%។

**ឧទាហរណ៍ទី៤៖**

លោក **ង** ជានិវាសនជន ត្រូវបានភាគហ៊ុនិករបស់ក្រុមហ៊ុន **ច** នៅប្រទេសកម្ពុជា ចាត់តាំងឱ្យធ្វើជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន **ច**។ គាត់ត្រូវបានអញ្ជើញមកចូលរួមកិច្ចប្រជុំពិភាក្សារបស់ក្រុមប្រឹក្សាភិបាលជារៀងរាល់ត្រីមាស ហើយគាត់ត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៤ ០០០ ០០០ រៀល សម្រាប់កិច្ចប្រជុំម្តងៗ។

ករណីនេះ ប្រាក់ឧបត្ថម្ភដែលលោក **ង** ទទួលបានមិនត្រូវចាត់ទុកជាប្រាក់បៀវត្ស និងមិនជាប់ពន្ធលើប្រាក់បៀវត្សទេ ប៉ុន្តែត្រូវជាប់ពន្ធកាត់ទុកតាមអត្រា ១៥% លើការបំពេញសេវា។

សមាជិកក្រុមប្រឹក្សាភិបាលឬនាយកក្រុមហ៊ុន ដែលបំពេញលក្ខខណ្ឌដូចខាងក្រោម មិនត្រូវជាប់ពន្ធលើប្រាក់បៀវត្សទេ៖

ក- ឈរឈ្មោះលើលក្ខន្តិកៈក្រុមហ៊ុនឬបណ្ណពន្ធប៉ាតង់ ប៉ុន្តែមិនមានវត្តមាននិងមិនមានតួនាទីគ្រប់គ្រងការងារជាប្រចាំនៅក្រុមហ៊ុននៅប្រទេសកម្ពុជា។

ខ- មានតួនាទីត្រឹមតែចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងកិច្ចប្រជុំភាគហ៊ុនិកម្តងម្កាលតែប៉ុណ្ណោះ។

គ- មិនទទួលបានប្រាក់បៀវត្សពីក្រុមហ៊ុននៅប្រទេសកម្ពុជា។

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់យ៉ាងមុតមាំថា លោក-លោកស្រីជាអភិបាលឬបណ្ណាធិការឬកម្មសិទ្ធិកររបស់សហគ្រាសទាំងអស់ នឹងយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំខាងលើឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

គង់ វិបុល